ព្រះរាជក្រម នស/រកម/០៦៩៩/០៨

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ហេតុព្រះរាជក្រមលេខ នស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧១ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតាត់តាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសឲ្យប្រើ

ច្បាប់ស្តីពី ការបង្កើតក្រសួងធនធានទឹក និងឧតុនិយម ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៩៩ នាសម័យប្រជុំរដ្ឋសភាលើកទី២ នីតិកាលទី២ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៩៩

នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី១ ហើយនិងដែលព្រឹទ្ធសភាបានពិនិត្យ និងយល់ព្រមទាំង
ស្រុងនូវទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដូចតទៅ :

ច្បាប់

ស្តីពី

ការបង្កើតក្រសួងធនធានទឹក និង ឧតុនិយម

មាត្រា ១.- ត្រូវបានបង្កើតក្រសួងធនធានទឹក និងឧតុនិយម ចំណុះរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រ
កម្ពុជា ។

មាត្រា ២.- ក្រសួងធនធានទឹក និងឧតុនិយម មានសមត្ថកិច្ចដឹកនាំ និងគ្រប់គ្រងលើវិស័យធនធានទឹក
និងឧតុនិយម នៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣.- ក្រសួងធនធានទឹក និងឧតុនិយម ត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអាចមានជំនួយដោយ
រដ្ឋលេខាធិការ និង / ឬអនុរដ្ឋលេខាធិការតាមការចាំបាច់។

មាត្រា ៤.- ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅនៃក្រសួងធនធានទឹក និងឧតុនិយមត្រូវកំណត់
ដោយអនុក្រឹត្យ ។

មាត្រា ៥.- បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦.- ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★